គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ..៥៩៧..ស.ល..../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី.១៧. ខែ.មិថុនា. ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ សំណើសុំធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិចសម្រាប់ប្រើប្រាស់ចាប់ពីឆ្នាំ២០១៧។

**យោង** ៖ - ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

- សេចក្តីសម្រេចលេខ ០០១ សសរ/គ.ជ.វ.វ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ដែលត្រូវបានកែសម្រួលលើកទី២។

- សេចក្តីសម្រេចលេខ ០៧០សសរ/គ.ជ.អ.ប. ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវបញ្ជីបច្ចុប្បន្នភាពតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងបញ្ជីបច្ចុប្បន្នភាពតំបន់ជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិច សម្រាប់ប្រើប្រាស់ក្នុងគម្រោងមូលនិធិឃុំ សង្កាត់ ក៏ដូចជាក្នុងគម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តផងដែរ។ បច្ចុប្បន្នការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់បានអនុវត្តដោយប្រើប្រាស់បញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ តាមសេចក្តីសម្រេចលេខសេចក្តីសម្រេចលេខ ០៧០សសរ/គ.ជ.អ.ប. ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១២។ តាមរយៈការអនុវត្តកន្លងមក ខេត្តមួយចំនួន បានលើកឡើងពីការលំបាកក្នុងការសិក្សាផលប៉ះពាល់បរិស្ថានក្នុងការអនុវត្តគម្រោងឃុំ សង្កាត់ ដោយសារបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិចដែលកំពុងប្រើប្រាស់សព្វថ្ងៃនេះ មានភាពលំអៀង និងខ្វះសុក្រឹតភាពព្រោះឃុំ សង្កាត់មួយចំនួនមានការប្រែប្រួលស្ថានភាពបរិស្ថាន និងជនជាតិដើមភាគតិច ហើយបានបង្កជាបញ្ហាលំបាកផ្សេងៗសម្រាប់ការរៀបចំ និងការអនុវត្តគម្រោងទៀតផង។

ដើម្បីដោះស្រាយការលំបាក និងដោយមើលឃើញពីតម្រូវការរបស់ថ្នាក់ក្រោមជាតិនេះ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីទាំងពីរសម្រាប់ប្រើប្រាស់ទូទាំងប្រទេស។

ដើម្បីធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីទាំងពីរនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ស្នើឯកឧត្តមមេត្តារៀបចំក្រុមការងារ ឬគណៈកម្មការតាមរាជធានីខេត្តនីមួយៗដោយមានសមាសភាពចូលរួមពីអ្នកពាក់ព័ន្ធនានា។ រាជធានី ខេត្តនីមួយៗត្រូវធ្វើបច្ចុប្បន្នភាពតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិចដែលពាក់ព័ន្ធនឹងឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួនឱ្យបានរួចរាល់ក្នុងខែសីហាឆ្នាំ២០១៦ និងត្រូវផ្ញើបញ្ជីដែលត្រូវធ្វើបច្ចុប្បន្នភាពនេះមកលេខាធិការដ្ឋាន គ.ជ.អ.ប. ឱ្យបានមុនថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦។

សម្រាប់ព័ត៌មានលម្អិត ខ្ញុំសូមជូនភ្ជាប់ជាមួយនូវបញ្ជីទាំងពីរ ដើម្បីឯកឧត្តមមានអនុសាសន៍លុបចេញឬបន្ថែមឃុំ សង្កាត់មួយចំនួនដែលតម្រូវការ ឬមិនតម្រូវការសិក្សាផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិចក្នុងការអនុវត្តគម្រោង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងដោយអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ជ.-ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**